


# We’re developing a new vision for the 710 corridor.

I-710 TASK FORCE

Metro

# សូមស្វាគមន៍!

*យើងនឹងចាប់ផ្តើមនៅពេលបន្តិចទៀ
ត។*

**កិច្ចប្រជុំក្រុមការងារផ្លូវលេខ 710 #8៖**

ថ្ងៃទី9 ខែឧសភា ឆ្នាំ2022

# អ្នកសម្របសម្រួល



**Erika C.B. Morales**

Partner, Morales + Morales Partners

# Metro Team



**KeAndra Cylear Dodds**

LA Metro, Equity and Race



**Ernesto Chaves**

LA Metro, Highway Programs



**Jessica Medina**

LA Metro, Equity and Race



**Lilian De Loza-Gutierrez**

LA Metro, Community Relations



**Michael Cano**

LA Metro, Countywide Planning

Metro

# Interpretation / *Interpretación /kar bakasray / Interpretasyon*

**To listen to the meeting in another language:**

***Español*:**

- *Llamada en español:* 872.240.3212
- *Código de acceso:* 514-659-501

***Khmer:***

- *សេចក្ដីលម្អិត អំពីការហៅចូលប្រជុំ:* 786.535.3211
- *លេខកូដចូលប្រើ:* 856-303-189

***Tagalog:***

- *Mga Detalye sa Call-in sa Pagpupulong:* 872.240.3212
- *Kodigo:* 933-864-189

**Tech Support - Google phone line/text**

- Phone: 323.609.3345
- Monitoring, translation support

Metro

# Task Force Member Identification

**Task Force Members, please change your Zoom screen name to include:** Name and Organization Name



# Raise Hand / *Levantar la mano*

- Click **Raise Hand** in your meeting controls or
- **Press*9** on the phone line.
- To lower your hand, click **Raise Hand** in your meeting controls.
- Comments & questions can also be provided in writing by using the **Q&A** function.
- The **Q&A** button is located on the control panel at the bottom of your screen.
- If you're listening in on our Spanish, Khmer or Tagalog **phone** call-in lines and have a question or comment, please **press *6** to unmute yourself and let the interpreter know.

- *Haga clic en "**Raise Hand**" o "**Levantar la mano**" en los controles de la reunión o*
- ***Presiona *9** en la línea telefónica.*
- *Para bajar la mano, haga clic en "**Raise Hand**" o "**Levantar la mano**" en los controles de la reunión.*
- *Los comentarios y las preguntas también se pueden proporcionar por escrito mediante la función de **Q&A**.*
- *El botón **Q&A** se encuentra en el panel de control en la parte inferior de la pantalla.*
- *Si está escuchando nuestras líneas telefónicas en español, jemer o tagalo y tiene una pregunta o comentario, presione * 6 para abrir la línea y avisar al intérprete.*

Metro

# សូមស្វាគមន៍!

# វត្ថុបំណងនៃកិច្ចប្រជុំ

- បញ្ជាក់ទទួលសមាជិកថ្មីនៃគណៈកម្មាធិការដឹកនាំសហគមន៍ (CLC)
- ពិភាក្សាអំពីមតិយោបល់ត្រឡប់ទៅលើចក្ខុវិស័យ គោលដៅ & វត្ថុបំណង
- ធ្វើបទបង្ហាញអំពីសំណើសុំណែនាំអំពី “សមធម៌” និង “និរន្តរភាព” ជាគោលការណ៍ដឹកនាំ
- ពិនិត្យ និងពិភាក្សាអំពីសេចក្តីព្រាងនៃសេចក្តីថ្លែង ចក្ខុវិស័យនិងគោលដៅ
- ចូលរួមក្នុងការបង្កើតមតិរួម ដើម្បីកែលម្អសេចក្តីព្រាងនៃសេចក្តីថ្លែង ចក្ខុវិស័យនិងគោលដៅ

Metro

# របៀបវារៈ

5:00 ល្ងាច  ការស្វាគមន៍ ការណែនាំឱ្យស្គាល់ ការពិនិត្យមើលរបៀបវារៈ និងវត្ថុបំណងអង្គប្រជុំ

5:10 ល្ងាច   របៀបវារៈ #1៖  ក្រុមការងារបញ្ជាក់ទទួល Sinetta Farley ជាសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍

5:30 ល្ងាច   របៀបវារៈ #2៖  សេចក្តីព្រាងនៃសេចក្តីថ្លែង ចក្ខុវិស័យ & គោលដៅ សម្រាប់តំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង

6:55 ល្ងាច   របៀបវារៈ #3៖  របាយការណ៍ល្អិត របស់ ក្រុមការងារគម្រោង និងក្រុមការងារ

7:15 យប់   មតិយោបល់សាធារណៈទូទៅ និងសុន្ទរកថាបិទបញ្ចប់

7:25 យប់  ការប្រជុំនាពេលខាងមុខ

Metro

# របៀបវារៈលម្អិត

5:00 ល្ងាច   ការស្វាគមន៍ ការណែនាំឱ្យស្គាល់ ការពិនិត្យមើលរបៀបវារៈ និងវត្ថុបំណងអង្គប្រជុំ (10នាទី)

5:10 ល្ងាច   របៀបវារៈ #1៖  ក្រុមការងារបញ្ជាក់ទទួល Sinetta Farley ជាសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ (20នាទី)

1.1 សំណើ (5នាទី)

i. ការពិភាក្សារបស់ក្រុមការងារ (5នាទី)

ii. មតិយោបល់សាធារណៈ (5នាទី)

iii. ការបោះឆ្នោត (5នាទី)

5:30 ល្ងាច   របៀបវារៈ #2៖  សេចក្តីព្រាងនៃសេចក្តីថ្លែង ចក្ខុវិស័យ & គោលដៅ សម្រាប់តំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង (85នាទី)

2.1 ការធ្វើបច្ចុប្បន្នភាពរយៈពេលកំណត់ និងការសង្ខេបចំណុចសំខាន់នៃមតិចូលរួមដែលទទួលបាន (10នាទី)៖

i. កិច្ចប្រជុំរបស់គណៈកម្មាធិការដឹកនាំសហគមន៍ #2

ii. កិច្ចប្រជុំរបស់ក្រុមការងារសមធម៌ #2

iii. កិច្ចប្រជុំ ក្រុមការងារ #7

2.2 គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង និងគោលការណ៍ដឹកនាំ (25នាទី)

i. បង្ហាញអំពីគោលការណ៍ដឹកនាំ

ii. ពិភាក្សាសំណើសុំគោលការណ៍ដឹកនាំស្តីពីសមធម៌

• ការសាកល្បងសម្រាប់មតិរួម

iii. ពិភាក្សាសំណើសុំគោលការណ៍ដឹកនាំស្តីពីនិរន្តរភាព

• ការសាកល្បងសម្រាប់មតិរួម

2.3 ការពិភាក្សាទៅវិញទៅមក ស្តីពីសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ (20នាទី)

i. ផ្តល់មតិចូលរួម និងចែករំលែកគំនិតទៅលើសេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ

2.4 ការកែលម្អសេចក្តីព្រាងនៃសេចក្តីថ្លែង ចក្ខុវិស័យ & គោលដៅ (30នាទី)

i. ការពិភាក្សារបស់ក្រុមការងារ (25នាទី)

ii.  មតិយោបល់សាធារណៈ (5នាទី)

6:55 ល្ងាច   របៀបវារៈ #3៖  របាយការណ៍លម្អិត របស់ ក្រុមការងារគម្រោង និងក្រុមការងារ (20នាទី)

3.1 កិច្ចប្រជុំរបស់គណៈកម្មាធិការដឹកនាំសហគមន៍ #2

3.2 កិច្ចប្រជុំក្រុមការងារ #7

3.3 កិច្ចប្រជុំក្រុមការងាររថយន្តដឹកទំនិញមិនបញ្ចេញផ្សែងពុល #5

3.4 កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #1

7:15 យប់  មតិយោបល់សាធារណៈទូទៅ និងសុន្ទរកថាបិទបញ្ចប់ (10នាទី)

7:25 ល្ងាច   កិច្ចប្រជុំខាងមុខ (5នាទី)

Metro






Find more project materials at: https://www.metro.net/projects/i-710-corridor/#documents



Metro
What is your position on the preliminary vision statement?
43% I support it!
29% I can live with it
21% I have concerns
Community Leadership Committee
17 members in attendance
5 open seats
Key Topics
Zero emmissions
Pollution reduction
Multi-modal transportation
I-710 South Corridor EIR/EIS
Thank you for your participation!
Clean air is important!
Zero emissions!
Go Dodgers!
Task 710 Force
Meeting Seven
Public Comment
No build today for a new vision tomorrow
Investment strategy
Develop vision
Re-engage impacted communities
Identify community needs
Discussed challenges & opportunities
Role of EWG
Reviewed definitions
Equity Working Group
Voted to confirm CLC member list
Project Teams
Report out
Next Steps
And make sure we're all on the same pages!
Work with Caltrans to complete documents
Coordinate with regional, state & feds
the sketch effect
Visual Communication Solutions

# នាទីល្ងាច របៀបវារៈ #1៖
# ក្រុមការងារបញ្ជាក់ទទួល Sinetta Farley ជាសមាជិកគ
# ណៈកម្មាធិការដឹកនាំសហគមន៍

# សមាជិកថ្មីសម្រាប់ការបញ្ជាក់ទទួលដោយក្រុមការងារ

សំណើ៖ បញ្ជាក់ទទួល Sinetta Farley ដែលជាអ្នករស់នៅ East/Rancho Dominguez ជាសមាជិកមួយរូប នៃ គណៈកម្មា ធិការ ដឹកនាំ ស ហគម ន៍។

Metro

# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 1នាទី ដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។

01:00

Start | Stop | Reset | mins: 1 | secs: 0 | type: None

Breaktime for PowerPoint by Flow Simulation Ltd.

Pin controls when stopped

Metro

# ការបោះឆ្នោតរបស់ក្រុមការងារដើម្បីបញ្ជាក់ទទួលសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ (CLC)




- ការបោះឆ្នោតដើម្បីបញ្ជាក់ទទួល Sinetta Farley ដែលជាអ្នករស់នៅ East/Rancho Dominguez ជាសមាជិកមួយរូបនៃ CLC

# នាទីលាច របៀបវារៈ #2៖
# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ
# សម្រាប់តំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង

Metro

# នាទីល្ងាច របៀបវារៈ #2.1៖ សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅសម្រាប់តំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង

Metro

# សេចក្តីថ្លែងការណ៍ចក្ខុវិស័យ និងការកំណត់ពេលវេលាអភិវឌ្ឍន៍គោលដៅ

រយៈពេលកំណត់នេះបង្ហាញពីសកម្មភាពសំខាន់ៗ និងកាលបរិច្ឆេទសម្រាប់ការបង្កើតសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅរបស់ក្រុមការងារផ្លូវ 710 ។

## ខែកុម្ភៈ

**ថ្ងៃទី17 ខែកុម្ភៈ –** ណែនាំដំណាក់កាលរៀបចំចក្ខុវិស័យ & គោលដៅ នៅ ក្នុង កិច្ច ប្រជុំក្រុមការងារ # 5

**ថ្ងៃទី22 ខែកុម្ភៈ –** ចាប់ផ្តើមការស្ទង់មតិអំពីចក្ខុវិស័យ & គោលដៅ

**ថ្ងៃទី23 ខែកុម្ភៈ** - ពិភាក្សាអំពីការផ្សព្វផ្សាយការស្ទង់មតិ និងទម្រង់ សិក្ខាសាលានៅឯកិច្ចប្រជុំ ក្រុមការងារ យុទ្ធសាស្ត្រ ចូលរួម ជាមួយ សហគមន៍

## ខែមីនា

**ដើមខែមីនា -** ក្រុមការងារគម្រោងពិនិត្យលទ្ធផលស្ទង់មតិ បង្កើតសេចក្តីព្រាងបឋមអំពីសេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅ

**ថ្ងៃទី14 ខែមីនា –** បង្ហាញលទ្ធផលស្ទង់មតិបឋម និងសេចក្តីព្រាង ដំបូងអំពីសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅនៅ ក្នុងកិច្ចប្រជុំ ក្រុមការងារ #6

**ថ្ងៃទី23 ខែមីនា** – កិច្ចប្រជុំសាធារណៈស្តីពីការអភិវឌ្ឍគោលដៅ & ចក្ខុវិស័យ
ថ្ងៃទី30 ខែមីនា – បិទការស្ទង់មតិអំពីចក្ខុវិស័យនិងគោលដៅ

**ថ្ងៃទី31 ខែមីនា –** ពិភាក្សាចក្ខុវិស័យ & គោលដៅនៅឯកិច្ចប្រជុំចាប់ផ្តើមនៃ គណៈកម្មាធិការដឹកនាំសហគមន៍ (CLC)

## ខែមេសា

**ដើមខែមេសា –** ក្រុមការងារគម្រោងបញ្ចូលមតិចូលរួមទៅក្នុងសេចក្តីព្រាង ចុងក្រោយអំពីសេចក្តីថ្លែង ចក្ខុវិស័យ និងគោលដៅ

**ថ្ងៃទី5 ខែមេសា –** ពិភាក្សាអំពីចក្ខុវិស័យ & គោលដៅ ដែលបានមកពីទស្សនៈសមធម៌នៅឯកិច្ចប្រជុំចាប់ផ្តើមរបស់ក្រុមការងារសមធម៌

**ថ្ងៃទី11 ខែមេសា –** ការពិនិត្យមើលសេចក្តីព្រាងចក្ខុវិស័យនិងគោលដៅ នៅក្នុងកិច្ចប្រជុំក្រុមការងារ #7

**ថ្ងៃទី19 ខែមេសា–** ការពិនិត្យមើលមតិចូលរួមសាធារណៈស្តីពីចក្ខុវិស័យ & គោលដៅ នៅកិច្ចប្រជុំ CLC #2។

**ថ្ងៃទី19 ខែមេសា –** កិច្ចប្រជុំក្រុមការងារសមធម៌ #2 ណែនាំការកែលម្អទៅលើសេចក្តីព្រាងចក្ខុវិស័យនិងគោលដៅ ដែលបានមកពីទស្សនៈសមធម៌

**ថ្ងៃទី28 ខែមេសា** – កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #1 - ការធ្វើបច្ចុប្បន្នភាព ដំណាក់កាល បង្កើត សេចក្តី ថ្លែង ចក្ខុវិស័យនិងគោលដៅ

## ខែឧសភា

**ថ្ងៃទី9 ខែឧសភា –** កិច្ចប្រជុំក្រុមការងារ #8 កែលម្អសេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ

**ការបន្តចូលរួមរបស់សាធារណៈជន –** សមាជិកក្រុមការងារ និងសមាជិកសាធារណៈជនអាចដាក់ជូន មតិយោបល់ជាលាយលក្ខណ៍អក្សរ អ៊ីមែល ឬលិខិត ទៅកាន់ Metro (ទីភ្នាក់ងារប្រព័ន្ធរថភ្លើងក្រោមដី) និង Caltrans (ក្រសួងដឹកជញ្ជូនរដ្ឋ California) ដើម្បីផ្តល់ជូននូវ មតិចូលរួមលើការអភិវឌ្ឍ និងការអនុម័តសេចក្តីថ្លែងការណ៍ ចក្ខុវិស័យ & គោលដៅ សមាជិកសាធារណៈ ក៏អាចផ្តល់មតិយោបល់ជាសាធារណៈនៅអំឡុងកិច្ចប្រជុំក្រុមការងារ #5, 6, 7 និង 8 ។

យើងនៅទីនេះ

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**ចក្ខុវិស័យ**

សេចក្តីថ្លែងសង្ខេបដែលរៀបរាប់អំពីមហិច្ឆតា បំណងប្រាថ្នា និងលទ្ធផលរួមនៃគម្រោង

**ចក្ខុវិស័យ:**

*សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ (ថ្ងៃទី11 ខែមេសា ឆ្នាំ2022)៖ ប្រព័ន្ធការដឹកញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពធន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់នៃតំបន់ខ្សែបន្ទាត់ផ្លូវលេខ I-710 ភាគខាងត្បូង។*

Metro

# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ – មតិចូលរួមរបស់គណៈកម្មាធិការដឹកនាំសហគមន៍

- ត្រូវប្រាកដថាភាសាទាំងអស់គឺងាយស្រួលយល់។ ប្រើពាក្យពេចន៍ ដែលងាយយល់ និងធ្វើឱ្យវាមានភាពសមស្របទៅនឹងសហគមន៍
- រួមបញ្ចូលសុខភាពសាធារណៈជាចំណុចអាទិភាព
- ត្រូវប្រាកដថាសេចក្តីថ្លែងនោះចាត់ទុក “សហគមន៍” ជា អាទិភាព
- ធ្វើឱ្យគោលការណ៍ដឹកនាំមានភាពជាក់លាក់ និងសូវមិនមានលក្ខណៈទូទៅ ដោយសំដៅ ជាពិសេស ដល់អ្នក រស់ នៅ លើផ្លូវលេខ 710
- សេចក្តីថ្លែងជាភាសាអេស្ប៉ាញ និងអង់គ្លេស អាចនឹងចាំបាច់ត្រូវខុសគ្នាបន្តិចក្នុងការរៀបរាប់អំពីពាក្យពេចន៍ និងទស្សនៈដូចគ្នា

# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ – មតិចូលរួមរបស់គណៈកម្មាធិការដឹកនាំសហគមន៍

*(កិច្ចការកំពុងដំណើរការ– ត្រូវពិភាក្សាបន្ថែមក្នុងអំឡុងកិច្ចប្រជុំរបស់ CLC នៅក្នុងខែឧសភា)*

An equitable multi-modal (walking, taking public transportation, riding a bike, driving, etc.) shared transportation system for the community and residents which ~~promotes~~ fosters clean air, healthy and sustainable communities, economic ~~resilience~~ empowerment; and provides safe, quality mobility options for all residents and users of the I-710 South Corridor.

Metro

# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ – មតិចូលរួមរបស់ក្រុមការងារសមធម

- បានស្នើទៅកាន់ក្រុមការងារឱ្យជំនួសគោលដៅ "សមធម៌" និង "និរន្តរភាព" ដោយគោលការណ៍ដឹកនាំ
- បានស្នើទៅកាន់ក្រុមការងារឱ្យពិចារណាទៅលើគោលការណ៍ដឹកនាំសមធម៌
- បានស្នើទៅកាន់ក្រុមការងារឱ្យពិចារណាទៅលើសេចក្តីថ្លែងចក្ខុវិស័យដែលត្រូវបាន កែលម្អរួច

Metro

# សេចក្ដីព្រាងនៃសេចក្ដីថ្លែងចក្ខុវិស័យ – មតិចូលរួមរបស់ក្រុមការងារសមធម

An equitable ~~multi-modal~~ shared-use transportation system that ~~supports~~ promotes clean air, healthy and sustainable communities, economic resilience, and quality jobs; and provides safe, quality multi-modal mobility options for all residents and users of the I-710 South Corridor.

# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ – មតិចូលរួមរបស់ក្រុមការងារ

> បន្ថែមឯកសារយោងច្បាស់លាស់ដល់ “ចរាចរណ៍ទំនិញ” ដល់សេចក្តីថ្លែងចក្ខុវិស័យ

> ពិចារណាចាត់ទុក “សមធម៌” និង “និរន្តរភាព” ជាគោលការណ៍ដឹកនាំសម្រាប់សេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ

> កំណត់និយមន័យពាក្យពេចន៍នានាដើម្បីបង្កើនការយល់ដឹងអំពីសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ

Metro

# នាទីល្ងាច របៀបវារៈ #2.2៖ គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង និងគោលការណ៍ដឹកនាំ

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**ចក្ខុវិស័យ** សេចក្តីថ្លែងសង្ខេបដែលរៀបរាប់អំពីមហិច្ឆតា បំណងប្រាថ្នា និងលទ្ធផលរួមនៃគម្រោង

**ចក្ខុវិស័យ:**

*សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ (ថ្ងៃទី11 ខែមេសា ឆ្នាំ2022)៖*
*ប្រព័ន្ធការដឹកជញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពធន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់នៃតំបន់ខ្សែបន្ទាត់ផ្លូវលេខ I-710 ភាគខាងត្បូង។*

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**គោលដៅ** លទ្ធផលដែលចង់បានសម្រាប់តំបន់ដែលមានក្តីបារម្ភ ដើម្បីគាំទ្រនិងសម្រេចបានចក្ខុវិស័យជារួម

**ចក្ខុវិស័យ** → **គោលដៅ៖**

**គុណភាពខ្យល់**
ពង្រឹងគុណភាពខ្យល់

**សហគមន៍**
កែលម្អសុខភាពនិងគុណភាពជីវិតរបស់អ្នករស់នៅ និងស្ថិរភាពរបស់សហគមន៍

**ចល័តភាព**
កែលម្អការបំលាស់ទីរបស់ប្រជាជននិងទំនិញ

**សុវត្ថិភាព**
ផ្តល់សហគមន៍ ផ្លូវថ្នល់ និងវិថីដែលមានសុវត្ថិភាព

**សេដ្ឋកិច្ច**
ផ្តល់ការងារដែលមានគុណភាព ការអភិវឌ្ឍកម្លាំងការងារ និងឱកាសសេដ្ឋកិច្ច

**និរន្តរភាព និងបរិស្ថាន**
ដោះស្រាយការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យបរិស្ថានប្រសើរឡើង

**សមធម៌**
កាត់បន្ថយ ឬលុបបំបាត់ភាពខុសគ្នាក្នុងសហគមន៍នៅទូទាំងគ្រប់គោលដៅ

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង




មតិយោបល់ត្រឡប់របស់ក្រុមការងារសមធម៌ និងក្រុមការងារផ្លូវបានគូសបញ្ជាក់ថាសមធម៌ និងនិរន្តរភាពគឺមានភាពទូលំទូលាយ និងពហុកម្រិត ដែលអនុវត្តចំពោះគ្រប់ទូទាំងគោលដៅ និងវត្ថុបំណងទាំងអស់។

Metro

# ការបង្ហាញអំពីគោលការណ៍ដឹកនាំ

**គោលការណ៍ដឹកនាំ**

គុណតម្លៃដែលដឹកនាំរាល់ដំណើរការនិងលទ្ធផលទាំងអស់ តាមរយៈក្របខណ្ឌពាក់ព័ន្ធគ្នា និងដោយចេតនា

## បានដាក់ស្នើគោលវិធី




Metro

# គោលដៅដំបូងរបស់តំបន់ខ្សែបន្ទាត់ផ្លូវលេខ 710 ភាគខាងត្បូង




Metro

# ហេតុអ្វីត្រូវណែនាំបង្ហាញអំពីសមធម៌និងនិរន្តរភាពសម្រាប់ជាគោលការណ៍ដឹកនាំ?

សមធម៌ & និរន្តរភាពអនុវត្តចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃផែនការវិនិយោគ និងក្រុមការងារតំបន់ខ្សែបន្ទាត់ផ្លូវលេខ 710 ភាគខាងត្បូង។

> គំរូពីមុន៖ ផែនការយុទ្ធសាស្ត្រចរាចរណ៍ទំនិញខោនធី LA (LA County Goods Movement Strategic Plan) ឆ្នាំ 2021

ជួយកំណត់និយមន័យសមធម៌និងនិរន្តរភាពបន្ថែមទៀត ដើម្បីសម្រេចបានការយល់ដឹងទូទៅ

> ឱកាសដើម្បីបញ្ជាក់ឱ្យច្បាស់នូវធាតុផ្សំពហុកម្រិតនៃសមធម៌និងយុត្តិធម៌ និងរបៀបដែលធាតុផ្សំទាំងនោះផ្សារភ្ជាប់ទៅនឹងដំណើរការរៀបចំធ្វើផែនការ៖ សមធម៌តាមបែបនីតិវិធី + មានលក្ខណៈចែកចាយ + ស្តារឡើងវិញ + ជារចនាសម្ព័ន្ធ

> ឱ្យនិយមន័យនៃនិរន្តរភាពដែលក្តោបអត្ថន័យទូលំទូលាយរបស់វា និងរបៀបដែលវាអនុវត្តចំពោះដំណើរការធ្វើផែនការ

> ឱ្យនិយមន័យនៃនិរន្តរភាពដែលក្តោបអត្ថន័យទូលំទូលាយរបស់វា និងរបៀបដែលវាអនុវត្តចំពោះដំណើរការធ្វើផែនការ

គោលការណ៍ដឹកនាំនឹង៖

> ជម្រាប ដំណឹង អំពី កិច្ច ដំណើរការនិងគំនិតផ្តួចផ្តើមនានានៅគ្រប់ដំណាក់កាលនៃគម្រោង

> ជួយដល់ ការពិភាក្សាគ្នា ជាក្រុម និងកំណត់អំពីចំណុចអាទិភាពនានា

> ផ្សារភ្ជាប់ធាតុផ្សំឯករាជ្យនានានៃការងារគម្រោង ទៅនឹងក្របខណ្ឌពាក់ព័ន្ធគ្នានិង ដោយ ចេតនា

> កាត់បន្ថយភាពច្រំ ដែលនៅក្នុងចំណោមវត្ថុបំណងនិងយុទ្ធសាស្ត្រ

Metro

# សេចក្តីថ្លែងគោលការណ៍ដឹកនាំសមធម៌ដែលបានដាក់ស្នើរបស់ EWG

*ផែនការវិនិយោគតំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង គឺមានមូលដ្ឋានគ្រឹះលើគោលការណ៍ដឹកនាំសមធម៌ ដែល ជា ការប្តេជ្ញាចិត្តក្នុងការៈ (1) ខិតខំប្រឹងប្រែងកែប្រែ បញ្ហាពីអតីតកាល (2) ផ្តល់លទ្ធភាពទទួលបានឱកាសដោយត្រឹមត្រូវ និងយុត្តិធម៌ និង 3) លុប បំបាត់ភាពល្អៀង ខុសគ្នានៅក្នុងដំណើរការនានារបស់គម្រោង ការសម្រេចបាន និង លទ្ធផលរបស់សហគមន៍។*

*ផែនការនោះគឺធ្វើយ៉ាងណាបង្កើននិងប ណ្តុះគោលការណ៍សមធម៌នៅគ្រប់ គោលដៅ វត្ថុបំណង យុទ្ធសាស្ត្រ និង វិធាន ការ ទាំងអស់ តាមរយៈក្របខណ្ឌសមធម៌តាមបែបនីតិវិធី មានលក្ខណៈចែកចាយ ជារចនាសម្ព័ន្ធ និង ស្តារឡើង វិញ និង តាមរយៈការផ្តោតអាទិភាព ទៅលើដំណើរការចូលរួមដែលអាចទទួលបាន និងមានលក្ខណៈជាតំណាង សម្រាប់ សហគមន៍ ដែលរងផលប៉ះពាល់បំផុតដោយគម្រោងផ្លូវ I-710។*

### សមធម៌តាមបែបនីតិវិធី

- ការនាំឱ្យមានចូលរួមពីសហគមន៍ដែលអាចទទួលបាន និងមានលក្ខណៈបរិសកម្ម ដែលផ្សាភ្ជាប់ គម្លាត ផ្នែក ភាសា បច្ចេកវិទ្យា និងសមត្ថភាព ទៅដល់សហគមន៍នានាដែលពួកគេតាំងនៅ និងអនុញ្ញាតឱ្យមាន ដំណើរការ ធ្វើ សេចក្តី សម្រេច ចិត្តបែបចូលរួម និង មាន លក្ខណៈជាតំណាង។
- ប្រព័ន្ធគណនេយ្យភាពនិងទំនាក់ទំនងដែលកំពុងដំណើរការដើម្បីកសាងនិងរក្សាទំនុកចិត្ត

### សមធម៍ដែលមានលក្ខណៈចែកចាយ

- ការបែងចែកអត្ថប្រយោជន៍និងគ្រឿងបរិក្ខារ ដែលសមមាត្រទៅនឹងកម្រិតតម្រូវការ និងការវិនិយោគ កាល ពី អតីត កាល និងផ្អែកលើអាទិភាពសហគមន៍ ដែលកំណត់ដោយខ្លួនឯង ជាជាងដំណោះស្រាយ "តែមួយដែល ត្រូវនឹង ស្ថានភាព ទាំងអស់"
- គោលនយោបាយ និងការគ្រប់គ្រងធនធាន ដើម្បីធានាថា អត្ថប្រយោជន៍ បានទៅដល់អ្នក ទទួល ដែល ត្រូវ បាន គ្រោងទុក

### សមធម៌ដែលមានលក្ខណៈស្តារឡើងវិញ

- ការទទួលស្គាល់ និងការប៉ះប៉ូវកែប្រែបញ្ហាពីអតីតកាល និងបញ្ហាជាប្រព័ន្ធដែលកំពុងកើតមាន ដែល បណ្តាល មក ពី ការ អនុវត្តការធ្វើផែនការ និងគោលនយោបាយ
- វិធានការ ធនធាន និងការវិនិយោគដែលស៊ីគ្នា ដែលបង្កើតឡើងដើម្បីកែលម្អ និងបង្កា បញ្ហា ជាប្រព័ន្ធ ជាបន្ត ទៀត ។

### សមធម៌ដែលមានលក្ខណៈរចនាសម្ព័ន្ធ

- ការវិវឌ្ឍនៃអង្គភាពធ្វើសេចក្តីសម្រេចចិត្ត ដើម្បីឆ្លុះបញ្ចាំងពីសហគមន៍ដែលពួកគេបម្រើសេវា
- រៀបចំ រចនាសម្ព័ន្ធឡើងវិញនៃប្រព័ន្ធ បែបស្ថាប័ន នឹងឋានានុក្រម ដើម្បីផ្តល់អំណាចដល់ក្រុម ដែលគេ មិន ឱ្យ តម្លៃ កាលពីអតីតកាល

Metro

# មតិរួម ដើម្បីពិភាក្សាដោយប្រើប្រាស់គោលការណ៍

## តើអ្នកមានទស្សនៈយ៉ាងណាចំពោះការប្រើប្រាស់ គោលការណ៍ដឹកនាំសម្រាប់សមធម៌ ?




Metro

# សេចក្តីថ្លែងគោលការណ៍ដឹកនាំនិរន្តរភាពដែលបានដាក់ស្នើ

- ផែនការវិនិយោគតំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង គឺមានមូលដ្ឋានគ្រឹះលើគោលការណ៍ដឹកនាំនិរន្តរភាព ៖ “ការអភិវឌ្ឍដែលបំពេញតាមតម្រូវការនាពេលបច្ចុប្បន្ន ដោយមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាព របស់មនុស្សជំនាន់ ក្រោ យ ក្នុងការបំពេញតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ”។
- *“ការប្តេជ្ញាចិត្តទៅលើនិរន្តរភាពគឺជាការបំពេញបាននូវតម្រូវការសង្គម និងសេដ្ឋកិច្ចជាមូលដ្ឋាន ទាំងនាពេលបច្ចុប្បន្ននិងអនាគត និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយទំនួលខុសត្រូវ ទាំងអស់នេះខណៈរក្សាបាន ឬកែលម្អសុខុមាលភាពបរិស្ថានដែលជីវិតពឹងផ្អែកលើ។”*

### និរន្តរភាពសេដ្ឋកិច្ច

- ផ្តោតលើការអនុវត្តដែលគាំទ្រការរីកចម្រើនផ្នែកសេដ្ឋកិច្ចរយៈពេលវែង ដោយមិនផ្តល់ផលប៉ះពាល់ជាអវិជ្ជមានលើទិដ្ឋភាពសង្គម បរិស្ថាន និងវប្បធម៌របស់សហគមន៍។

### និរន្តរភាពសង្គម

- ផ្តោតលើតម្រូវការសង្គមជាមូលដ្ឋានរបស់មនុស្ស រួមមានសុខភាពនិងសុខុមាលភាព ការអប់រំ កិត្តិយស សន្តិភាព និងយុត្តិធម៌។

### និរន្តរភាពបរិស្ថាន

- ផ្តីជាទំនួលខុសត្រូវក្នុងការថែរក្សាធនធានធម្មជាតិ និងការពារប្រព័ន្ធអេកូឡូស៊ីសកល ដើម្បីគាំពារសុខភាព និងសុខុមាលភាព នាពេលបច្ចុប្បន្ននិងអនាគត។

Metro

# មតិរួម ដើម្បីពិភាក្សាដោយប្រើប្រាស់គោលការណ៍

តើអ្នកមានទស្សនៈយ៉ាងណាចំពោះការប្រើប្រាស់ គោលការណ៍ដឹកនាំសម្រាប់និរន្តរភាព ?




Metro

# នាទីល្ងាច របៀបវារៈ #2.3៖
# ការពិភាក្សាទៅវិញទៅមកស្តីពីសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**ចក្ខុវិស័យ** សេចក្តីថ្លែងសង្ខេបដែលរៀបរាប់អំពីមហិច្ឆតា បំណងប្រាថ្នា និងលទ្ធផលរួមនៃគម្រោង

**ចក្ខុវិស័យ:**

*សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ (ថ្ងៃទី11 ខែមេសា ឆ្នាំ2022)៖*
*ប្រព័ន្ធការដឹកជញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពធន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់នៃតំបន់ខ្សែបន្ទាត់ផ្លូវលេខ I-710 ភាគខាងត្បូង។*

Metro

# គោលការណ៍ដឹកនាំ

**គោលការណ៍ដឹកនាំ**

គុណតម្លៃដែលដឹកនាំរាល់ដំណើរការនិងលទ្ធផលទាំងអស់ តាមរយៈក្របខណ្ឌពាក់ព័ន្ធគ្នា និងដោយចេតនា




Metro

# សេចក្តីព្រាងគោលដៅរបស់តំបន់ខ្សែបន្ទាត់ផ្លូវលេខ 710 ភាគខាងត្បូង




Metro

# គោលដៅ៖ ឧទាហរណ៍នៃមតិចូលរួមរបស់ក្រុមការងារ (វត្ថុបំណង)

> **គោលដៅ៖ កែលម្អចល័តភាពរបស់ប្រជាជននិងទំនិញ**

> វត្ថុបំណង៖ (ក្រុមការងារបានផ្តល់ជូនជាគោលដៅដែលត្រូវបានណែនាំ)
- បង្កើនជម្រើសដឹកជញ្ជូនពហុមធ្យោបាយ
- អនុវត្តដំណោះស្រាយនវានុវត្តន៍
- ផ្តល់អាទិភាព ការប្រើប្រាស់ កង់ និង ការដឹកជញ្ជូន សាធារណៈ
- បង្កើនឱកាសចល័តភាពរួមគ្នា
- អនុវត្តហេដ្ឋារចនាសម្ព័ន្ធសម្រាប់លទ្ធភាពចូលប្រើប្រាស់ប្រកបដោយសមធម៌និងងាយស្រួល
- បង្កើនសារៈសំខាន់នៃផ្លូវស្នាក់នៅ + បណ្តាញផ្លូវមេល្បឿនលឿន និងផ្លូវក្នុងមូលដ្ឋាន

Metro

# គោលដៅ៖ ឧទាហរណ៍នៃមតិចូលរួមរបស់ក្រុមការងារ (យុទ្ធសាស្ត្រ)

> **គោលដៅ៖ កែលម្អចល័តភាពរបស់ប្រជាជននិងទំនិញ**

> យុទ្ធសាស្ត្រ៖ (ក្រុមការងារបានផ្ដល់ជូនជាគោលដៅដែលត្រូវបានណែនាំ) Increase use of Alameda Corridor

- បង្កើនការប្រើប្រាស់តំបន់ខ្សែបន្ទាត់ Alameda  Develop wide sidewalks across the 710 freeway
- អភិវឌ្ឍចញ្ចើមផ្លូវធំទូលាយនៅលើផ្លូវល្បឿនលឿនមិនគិតថ្លៃ 710
- ដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបចុងក្រោយបំផុត និងកំពុងមានសន្ទុះសម្រាប់ការទំនាក់ទំនងរវាងអ្នកបើកបរ និងប្រព័ន្ធគ្រប់គ្រងចរាចរណ៍
- ផ្ដល់ជូននូវផ្លូវដែកក្នុងតំបន់ដែលលឿនជាងមុន (រហ័ស មានចំណតតិច) នៅក្នុងតំបន់ខ្សែបន្ទាត់ ដើម្បី តភ្ជាប់ ស្ថានីយ៍ Los Angeles Union Station និងទីប្រជុំជនក្រុង Long Beach។
- អនុវត្តតំបន់ខ្សែបន្ទាត់ចរាចរណ៍ទំនិញអាទិភាពរបស់ជាតិដែលមិនបញ្ចេញផ្សែងពុល
- វិនិយោគលើជម្រើសមធ្យោបាយធ្វើដំណើរ - អាចថ្មើរជើងបាន ជិះកង់បាន និងមធ្យោបាយធ្វើដំណើរសាធារណៈឥតគិតថ្លៃ
- ពង្រីកប្រព័ន្ធដឹកជញ្ជូនរហ័សតាមរថយន្តក្រុង
- អនុវត្តយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយរយៈចម្ងាយម៉ាលយ៍ដែលបានធ្វើដំណើរ ធ្វើការជាមួយរដ្ឋាភិបាល និងនិយោជក ដើម្បីលើកទឹកចិត្តឲ្យមានការធ្វើដំណើរកាន់តែតិច ការធ្វើការពីចម្ងាយនៅផ្ទះកាន់តែច្រើន និងម៉ោងធ្វើការអាចបត់បែនបាន។

Metro

# នាទីល្ងាច របៀបវារៈ #2.4៖ ការកែលម្អសេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ

# ការពិភាក្សារបស់ក្រុមការងារ

Metro

# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 1នាទី ដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។

01:00

Start | Stop | Reset | mins: 1 | secs: 0 | type: None

Breaktime for PowerPoint by Flow Simulation Ltd.

Pin controls when stopped

# នាទីលាច របៀបវារៈ #3៖
# របាយការណ៍លម្អិតរបស់ក្រុមការងារគម្រោង និងក្រុមការងារ

Metro

# សង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដឹកនាំសហគមន៍ #2

## សេចក្តីសង្ខេប កិច្ចប្រជុំ #2

> -ធ្វើឡើងតាមរយៈកម្មវិធី Zoom អនឡាញនៅថ្ងៃព្រហស្បតិ៍ ទី21 ខែមេសា

> សមាជិក CLC ចំនួន -19 រូបកំពុងចូលរួម

## ការរំលេចផ្នែកសំខាន់ៗ

✓ បានចាប់ផ្តើមពិភាក្សា និងកែតម្រូវសេចក្តីថ្លែងចក្ខុវិស័យ

## ការគិតពីអនាគតនៃកិច្ចប្រជុំ

✓ - កិច្ចប្រជុំ 2 នឹងត្រូវបានធ្វើឡើងក្នុងខែនេះ ដើម្បីពិនិត្យមើលចក្ខុវិស័យនិងគោលដៅ

- ✓ 5/19 ម៉ោង 5-7ល្ងាច
- ✓ 5/23 ម៉ោង 5-7ល្ងាច

Metro

# សង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំក្រុមការងារ #7

## សេចក្តីសង្ខេប

> ធ្វើឡើងតាមរយៈកម្មវិធី Zoom អនឡាញនៅថ្ងៃចន្ទ ទី11 ខែមេសា ឆ្នាំ2022

> អ្នកចូលរួមចំនួន -61នាក់ (សមាជិកក្រុមការងារ/អ្នកជំនួសចំនួន 26នាក់ សមាជិកគណៈកម្មាធិការ CLC ចំនួន 7 នាក់ និងសមាជិកសាធារណៈចំនួន 38នាក់)

## ការរំលេចផ្នែកសំខាន់ៗ

✓ ទិដ្ឋភាពទូទៅនៃដំណើរការបង្កើតសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ

✓ ការពិភាក្សាអំពីសេចក្តីព្រាងដំបូងនៃសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ

✓ ការធ្វើបច្ចុប្បន្នភាពទៅលើជម្រើស "គ្មានប្រភេទសាងសង់សម្រាប់ចក្ខុវិស័យថ្មីនៅថ្ងៃស្អែក" នៃ EIR/EIS តំបន់ ខ្សែ បន្ទាត់ ផ្លូវ I-710 ភាគខាងត្បូង

Metro

# សង្ខេបចំណុចសំខាន់របស់ក្រុមការងាររថយន្តដឹកទំនិញ ដែលមិនបញ្ចេញផ្សែងពុល #5

## សេចក្តីសង្ខេប

> រៀបចំឡើងតាមប្រព័ន្ធ Zoom អនឡាញនៅថ្ងៃអង្គារ ទី19 ខែមេសា

> អ្នកចូលរួមចំនួន 27នាក់ (សមាជិកក្រុមការងារ/អ្នកជំនួសចំនួន 9នាក់ សមាជិកតាមរយៈតួនាទី ក្នុង អង្គភាព ចំនួន 7នាក់ សមាជិកគណៈកម្មាធិការ CLC ចំនួន 4នាក់ និងសមាជិកក្រុមការងារចំនួន 7នាក់)

## ការរំលេចផ្នែកសំខាន់ៗ

✓ យុទ្ធសាស្រ្តក្នុងការប្រើប្រាស់ទឹកប្រាក់ 50លានដុល្លាររបស់ Metro មូលនិធិសមធម៌ជាផ្លូវការដំបូងនៅកម្រិតថ្នាក់រដ្ឋ និងសហព័ន្ធ

✓ ការណែនាំរបស់កម្មវិធី ZET Program និងគោលនយោបាយពាក់ព័ន្ធ កម្មវិធី និង កាលកំណត់ សម្រាប់ ការ រីកចម្រើន ទៅកាន់ក្រុមប្រឹក្សារបស់ Metro

✓ យុទ្ធសាស្រ្តចូលរួមរបស់សហគមន៍

Metro

# សង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #1

## សេចក្តីសង្ខេប

> កិច្ចប្រជុំចាប់ផ្តើមបានធ្វើឡើងតាមរយៈកម្មវិធី Zoom នៅថ្ងៃអង្គារ ទី28 ខែមេសា ឆ្នាំ2022
> មានវត្តមានសមាជិកគណៈកម្មាធិការសម្របសម្រួលចំនួន 5នាក់
> កាលបរិច្ឆេទប្រជុំបន្ថែមគឺត្រូវការជាចាំបាច់ នៅដើមខែមេសា (មិនទាន់សម្រេច)

## ការរំលេចផ្នែកសំខាន់ៗ

✓ តួនាទី និងទំនួលខុសត្រូវរបស់សមាជិកគណៈកម្មាធិការសម្របសម្រួល
✓ ការគិតពីអនាគតនៃគម្រោង
✓ ឱកាស-ផលលំបាកនៃការផ្តល់ថវិកា

Metro

# នាទីល្ងាច របៀបវារៈ #4៖
# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅ - ជំហានបន្ទាប់

Metro

# សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅ - ជំហានបន្ទាប់

ដើម្បីបំពេញដំណាក់កាលចក្ខុវិស័យនិងគោលដៅ យើងត្រូវការដូចខាងក្រោម៖

- ✓ បន្តទាក់ទងទៅកាន់មនុស្សគ្រប់រូបដែលពាក់ព័ន្ធនៅក្នុងក្រុមការងារតំបន់ ខ្សែបន្ទាត់ផ្លូវ 710 ភាគខាងត្បូង គណៈកម្មា ធិការ CLC និងក្រុមការងារ និងបំពេញការហៅទូរសព្ទមួយទល់មួយ
- ✓ ទាក់ទងទៅកាន់អ្នក (សមាជិកក្រុមការងារ) នៅយប់នេះ
- ✓ កិច្ច ប្រជុំរបស់គណៈកម្មាធិការ CLC ចំនួនពីរនៅប៉ុន្មានសប្តាហ៍ក្រោយ
- ✓ ស្តង់ដាភាពជោគជ័យរបស់យើងគឺកិច្ច សហការជាមួយមនុស្ស គ្រប់គ្នា តាម រយៈដំណើរការនេះ ដើម្បី សម្រេច បាន ចក្ខុវិស័យនិងគោលដៅដែលបានកែលម្អ ដែលរួមបញ្ចូល នូវ មតិយល់ឃើញទាំងអស់នេះ។
- ✓ ក្តីសង្ឃឹមរបស់យើងគឺត្រូវបញ្ចប់ដំណើរការនេះត្រឹមខែមិថុនា
- ✓ យើងត្រូវការអ្នកទាំងអស់គ្នាឱ្យជួយយើងសម្រេចបានគោលដៅនោះ

Metro

# មតិយោបល់សាធារណៈទូទៅ និងសុន្ទរកថាបិទបញ្ចប់

Metro

# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 2នាទីដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។

02:00

Start | Stop | Reset | mins: 2 | secs: 0 | type: None

Breaktime for PowerPoint by Flow Simulation Ltd. Pin controls when stopped

Metro

# ការប្រជុំនាពេលខាងមុខ

## ក្រុមការងារផ្សេងៗ

> **កិច្ចប្រជុំក្រុមការងាររថយន្តដឹកទំនិញមិនបញ្ចេញផ្សែងពុល #6**

**ថ្ងៃអង្គារ ទី17 ខែឧសភា ម៉ោង 1-3 រសៀល**

> **ក្រុមការងារសមធម៌ #3**

**ថ្ងៃពុធ ទី18 ខែឧសភា ម៉ោង 5-7យប់**

## គណៈកម្មាធិការដឹកនាំសហគមន៍

> *កិច្ចប្រជុំ លើកទី #3*

*ថ្ងៃព្រហស្បតិ៍ ទី19 ខែឧសភា ម៉ោង 5-7 យប់*

## គណៈកម្មាធិការសម្របសម្រួល Coordinating Committee

> *ថ្ងៃពុធ ទី25 ខែឧសភា មិនទាន់សម្រេច  Wednesday, May 25, TBD*

## ក្រុមការងារ Task Force

> កិច្ចប្រជុំ ក្រុមការងារ #9

ថ្ងៃចន្ទ ទី13 ខែមិថុនា ម៉ោង 5-7:30 យប់

Metro

# រក្សាទំនាក់ទំនងជាមួយគម្រោងនេះ។

Michael Cano, *Executive Officer (Interim)*
*Countywide Planning & Development*
Metro
One Gateway Plaza, MS 99-13-1
Los Angeles, CA 90012

213.922.4710

*710corridor@metro.net*

*metro.net/projects/i-710-corridor*

*@metrolosangeles*

*losangelesmetro*

Metro

# សូមអរគុណសម្រាប់ការចូលរួមជាមួយពួកយើង!

Metro